**ព្រះរាជាណាចក្រ កម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការកំពូល**
សំណុំរឿង រដ្ឋប្បវេណី
លេខ:៤៧៧
ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០០៣
**សាលដីកា**
លេខ:២៤
ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០០៥

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការកំពូល**

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០០៥ ដោយមានសមាសភាពដូចតទៅ:

១-ឯកឧត្តម **ឌឹត មុន្នី** ជាប្រធាន
២-លោក **ស៊ិន ឌឹម** ជាចៅក្រម
៣-លោក **ជីវ កេង** ជាចៅក្រមរបាយការណ៍
៤-លោក **ប្រាក់ គឹមសាន** ជាចៅក្រម
៥-លោក **ឈឹម ស៊ីផល** ជាចៅក្រម
៦-លោក គង់ ភីរុន ជាចៅក្រម
៧-លោក យស់ សូខឿន ជាចៅក្រម
៨-លោក សោម សិរីវឌ្ឍ ជាចៅក្រមរាបាយការណ៍
៩-លោក យូរ ឧត្តរា ជាចៅក្រម

**ក្រឡាបញ្ជី**
-លោក **អ៊ូ សុផុន**

**តំណាងមហាអយ្យការ**
-លោក **ឈួន ចាន់ថា** ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខលើកទី២ ពីសាលដីការដ្ឋប្បវេណីលេខ១៥៩(ង)ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៣ នៃសំណុំរឿងរដ្ឋប្បវេណីលេខ៥១ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍រវាង :

ដើមចោទឈ្មោះមាស សុគន្ធ (ជាម្ចាស់បណ្តឹងសាទុក្ខ) ភេទស្រី តំណាងដោយឈ្មោះម៉ៃ វ៉ាន់ឌី អាយុ៣០ឆ្នាំ ជាតិខ្មែរ មុខរបរលក់ដូរ ទីលំនៅសព្វថ្ងៃផ្ទះលេខ៤៣ ផ្លូវលេខ២៦៥ សង្កាត់ទឹកល្អក់៣ ខណ្ឌទួលគោក ក្រុងភ្នំពេញ ។

មានមេធាវីលោកម៉ៅ សុភារិទ្ធិ ។

ចុងចម្លើយឈ្មោះលីម ឡេង (ជាម្ចាស់បណ្តឹងសាទុក្ខ) ភេទប្រុស តំណាងដោយប្រពន្ធឈ្មោះស្រី ដានី មុខរបរជាម្ចាស់ភោជនីយដ្ឋាន គ្រីស្ទីណាដារី លំនៅផ្ទះលេខ៨១ ផ្លូវលេខ៦៣ សង្កាត់បឹងរាំង ខណ្ឌដូនពេញ ក្រុងភ្នំពេញ ។

អ្នកស្រីទី គឹមស្រ៊ាន ជាមេធាវី និងជាតំណាង ។

លោកមេធាវី ឌី បូឌីម៉ា ។

តតិយជនឈ្មោះ ដូ កាពីន (ម្ចាស់បណ្តឹងសាទុក្ខ) ភេទប្រុសតំណាងឲ្យក្រុមហ៊ុនCambodia HK Garment (LTD) អាស័យដ្ឋានផ្ទះលេខ ៤០៧E មហាវិថីព្រះមុនីវង្ស សង្កាត់បឹងព្រលិត ខណ្ឌ៧មករា ក្រុងភ្នំពេញ ។

មានមេធាវី កញ្ញាម៉ៅ សុំវុទ្ធារី ជាអ្នកការពារ និងជាតំណាង ។

<u>កម្មវត្ថុបណ្តឹងៈ</u> ប្តឹងសុំរំលាយកិច្ចសន្យាជួល

បានឃើញបណ្តឹងសាទុក្ខលើកទី២ លេខ២១២ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០០៣ របស់អ្នកស្រីមាស សុគន្ធ និងបណ្តឹងសាទុក្ខលេខ២១៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៣ របស់មេធាវីកញ្ញា ម៉ៅ សំវុទ្ធារី ការពារឱ្យលោកដូ កាពីន និងបណ្តឹងសាទុក្ខលេខ៣៧៦ ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០០៣ របស់អ្នកស្រីស្រី ដានី មិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ១៥៩(ឈ) ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍លើសេចក្តីសម្រេចទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ៤៧៧ ចុះថ្ងៃទី២២ ខែធ្នូឆ្នាំ២០០៣ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី០៥-០៩-២០០០ របស់ឈ្មោះមាស សុគន្ធ តំណាងដោយលោកម៉ែ វ៉ាន់ឌី ម្តឹងសុំរំលាយកិច្ចសន្យាជួលពីឈ្មោះលីម ឡេង មានឈ្មោះស្រី ដានី ទទួលផ្ទេរសិទ្ធិ ដោយសំអាងហេតុថាចាប់តាំងពីក្រុមហ៊ុន(ចុងចម្លើយ)ចុះកិច្ចសន្យាជួលឃ្លាំងរបស់ខ្លួនមក ក្រុមហ៊ុននេះ តែងតែបង់ថ្លៃឈ្នួលឃ្លាំងឱ្យមកខ្លួនជាម្ចាស់ឃ្លាំងមានការយឺតយ៉ាវជានិច្ច ហើយមកដល់ខែ០៧-០៨-២០០០ នេះ លោកលឹម ឡេង មិនព្រមបង់ប្រាក់ថ្លៃឃ្លាំងឱ្យខ្លួនជាម្ចាស់ឃ្លាំងទេ ទើបខ្លួនប្តឹងសុំរំលាយកិច្ចសន្យាជួលឃ្លាំងចោល ហើយសុំរឹបអូសប្រាក់កក់ សុំឱ្យសងប្រាក់ឈ្នួលឃ្លាំងដែលជំពាក់ឱ្យគ្រប់ចំនួន សុំរឹបអូសយកប្រាក់ថ្លៃឈ្នួលឃ្លាំងដែលតុលាការបានឃាត់ទុកពីភាគីទី៣ទាំងអស់ ប្រគល់មកឱ្យខ្លួន ។

តាមបណ្តឹងតប ចុះថ្ងៃទី០៧-០៩-២០០១ របស់ឈ្មោះលឹម ឡេង ជាតំណាងក្រុមហ៊ុនគ្រីស្ទីណា បានបញ្ជាក់ថា ខ្លួនប្តឹងទាមទារ ៖

១-ប្រាក់កក់ចំនួន ៨ខែ

២-សងប្រាក់កំរៃចំនួន ១២៦.០០០ដុល្លា ជាប្រាក់ថ្លៃជួលឃ្លាំងបន្តរយៈពេល៧ឆ្នាំ

៣-ប្រាក់ចំនួន ៥៤.០០០ដុល្លា ដែលភាគីម្ចាស់ឃ្លាំងទទួលយកលើសពីភាគីវេង ឈុនសុាំង

៤-ប្រាក់ជំងឺចិត្តចំនួន ២០.០០០ដុល្លា ។

ការទាមទារខាងលើនេះ ភាគីខាងដើមបណ្តឹងតបបានសំអាងថា កិច្ចសន្យាជួលឃ្លាំងរវាង ក្រុមហ៊ុនខ្លួន និងភាគីលោកសូ សាមឿន អ្នកស្រីមាស សុគន្ធ ជាម្ចាស់ឃ្លាំងពិតជាបានកើតឡើង ប្រាកដមែន ដែលមានរយៈពេលជួល១០ឆ្នាំ ក្នុងតំលៃ៣.០០០ដុល្លា ក្នុង១ខែ ហើយតាមកិច្ចសន្យា ភាគីខ្លួនបានកក់មុនចំនួន ៨ខែហើយ ។ ចាប់ពីពេលបង្កើតកិច្ចសន្យា ភាគីទាំងពីរពុំមានបញ្ហាអ្វីនឹង គ្នាឡើយ ទើបតែមានកើតទំនាស់នៅក្នុងខែ០៦ និងខែ០៧ ដោយមានការបង់ប្រាក់ថ្លៃឈ្នួល យឺតយ៉ាវ ហើយភាគីខាងអ្នកស្រីមាស សុគន្ធ ផាកពិន័យចំនួន៣%ក្នុង១ថ្ងៃ ។ ក្នុងរយៈពេលនោះលោកលីម ឡេង បានលើកឡើងថា ខ្លួនបានទៅព្យាបាលរោគនៅប្រទេសបារាំង។ ទំនាស់នេះរវាងភាគីទាំងពីរបានធ្វើការចរចារគ្នានៅចំពោះមុខអាជ្ញាធរសង្កាត់ទឹកល្អក់៣ ហើយក៏មានការព្រមព្រៀងគ្នាក្នុងការធ្វើវិសោធនកម្ម កិច្ចសន្យា ត្រង់ចំណុចស្តីពីប្រាក់ពិន័យ ដោយហេតុថា កិច្ចសន្យា បានធ្វើឡើងជាពីរភាសា ហើយមានអត្ថន័យខុសគ្នា ។ ភាគីខ្លួនបានយកប្រាក់ថ្លៃឈ្នួលខែ៧ ទៅតម្កល់ទុកនៅសង្កាត់ ។ តែភាគីម្ចាស់ឃ្លាំង បានបដិសេធ មិនព្រមធ្វើការដោះស្រាយ ហើយប្តឹងមកតុលាការតែម្តង ។

តាមពាក្យសុំចុះថ្ងៃទី០១-០២-២០០១ របស់តតិយជន គឺក្រុមហ៊ុន Cambodia HK Gament(LTD) បញ្ជាក់ថា ខ្លួនបានធ្វើកិច្ចសន្យាជាមួយភាគី លោកលីម ឡេង ជាតំណាងក្រុម ហ៊ុនគ្រឹស្ទីណាក្នុងការជួលឃ្លាំង ដែលមានទីតាំងស្ថិតនៅដីឡូត៍លេខ ៤៤ ផ្លូវ២៦៥ សំរាប់រយៈពេល៥ឆ្នាំ ក្នុងតម្លៃ ៤៥០០ដុល្លាអាមេរិក ក្នុងមួយខែ ហើយខ្លួនបានកក់មុនចំនួន ៥៤០០០ដុល្លាអាមេរិក ក្រោយមកខ្លួនបានទទួលដីកាសម្រេចតាមពាក្យសុំលេខ៥៤(ក) ចុះថ្ងៃទី០៧-០៩-២០០០ ដែលបង្គាប់ ឱ្យខ្លួនយកប្រាក់តម្កល់ទុកនៅតុលាការក្រុងភ្នំពេញ ព្រោះឃ្លាំងនេះ ជាកម្មវត្ថុទំនាស់រវាងឈ្មោះ លឹមឡេង និងម្ចាស់ឃ្លាំង ។ ហើយហេតុការណ៍នេះ បានធ្វើឱ្យខ្លួនខាតបង់ប្រាក់កក់ជាច្រើន ដូចនេះសំណូមពរ :

-រំលាយកិច្ចសន្យារវាងខ្លួន និងលោកលឹម ឡេង

-ទាមទារប្រាក់កក់

- សុំជួលបន្ត

-ទាមទារជំងឺចិត្ត ៥.០០០ដុល្លា ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ១៥(ក) ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០០១របស់តុលាការក្រុង ភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ៖

១-ក/ទទួលពាក្យបណ្តឹងចុះ ថ្ងៃ ទី៥ ខែកញ្ញា ឆ្នាំ២០០០ របស់ឈ្មោះមាស សុគន្ធ ប្តឹងសុំរំលាយកិច្ចសន្យា ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ពីក្រុមហ៊ុនគ្រឹស្ទីណា ដែលមានលីម ឡេង ជាតំណាងទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

ខ/ទទួលពាក្យសុំចូលជាតតិយជន ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០១ របស់លោកហែម ហូរណារិទ្ធិ និង លោកស្រីម៉ៅ សំរុទ្ធារី មេធាវីតំណាងឱ្យឈ្មោះវេង ឈូនសុាំង ទុកជា ត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-ក/រំលាយចោលជាអសារបង់នូវកិច្ចសន្យាចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ដែលបានធ្វើឡើងរវាងឈ្មោះសូ សាមឿន និងប្រពន្ធឈ្មោះមាស សុគន្ធ ជាមួយក្រុមហ៊ុនគ្រីស្ទីណា ដែលមានលោកលឹម ឡេង ជាតំណាង ។

ខ-/រំលាយចោលជាអសារបង់នូវកិច្ចសន្យាចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ដែលធ្វើឡើងរវាងឈ្មោះវេង ឈុនសុាំងជាមួយក្រុមហ៊ុនគ្រីស្ទៅណាមានលោកលឹម ឡេង ជាតំណាងតាម មាត្រា១០៧ នៃក្រិត្យច្បាប់លេខ៣៨ ស្តីពីកិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យា ។

៣-ក/បង្គាប់ឱ្យក្រុមហ៊ុនគ្រីស្ទីណា ដែលមានឈ្មោះលឹម ឡេងជាតំណាងសងសំណងឱ្យទៅដើម-ចោទឈ្មោះមាស សុគន្ធ គឺ :

ប្រាក់ឈ្នួលឃ្លាំងចំនួនពីរខែ គឺខែកក្កដា ឆ្នាំ២០០០ ចំនួន ៦.០០០ដុល្លាអាមេរិក(ប្រាំមួយពាន់ដុល្លាអាមេរិក)ជំងឺចិត្តចំនួន ៦.០០០ដុល្លាអាមេរិក (ប្រាំមួយពាន់ដុល្លាអាមេរិក) សរុបចំនួន១២.០០០ ដុល្លាអាមេរិក (មួយម៉ឺនពីរពាន់ ដុល្លាអាមេរិក) ប្រាក់នេះ ត្រូវកាត់យកពីប្រាក់ចំនួន ២៤.០០០ ដុល្លាអាមេរិក (ពីរម៉ឺនបួនពាន់ដុល្លាអាមេរិក) ដែលចុងចម្លើយឈ្មោះលឹម ឡេង បានកក់ទុកនៅដើមចោទ រួចហើយ ប្រាក់នៅសល់១២.០០០ដុល្លាអាមេរិក (មួយម៉ឺនពីរពាន់ដុល្លាអាមេរិក)ត្រូវប្រគល់ឱ្យចុងចម្លើយវិញ ។

ខ/រឹបអូសប្រាក់ដែលតុលាការបានឃាត់ទុកពីឈ្មោះចូវ កាពីន តំណាងឱ្យឈ្មោះវេង ឈុនសុាំង មួយខែ ៣.០០០ដុល្លាអាមេរិក ។

តាមអំណាចដីកាចារលើពាក្យសុំលេខ៥៤(ក) ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០០០ ដោយបានចាប់អនុវត្តពីខែ កញ្ញា ឆ្នាំ២០០០ រហូតមកឱ្យឈ្មោះមាស សុគន្ធ ដែលជាម្ចាស់ឃ្លាំង ។

គ/បង្គាប់អោយក្រុមហ៊ុនគ្រីស្ទីណា ដែលមានលោកលឹម ឡេង ជាតំណាងសងសំណងឱ្យទៅឈ្មោះវេង ឈុនសុាំង ជាតតិយជន ដែលមានឈ្មោះ ហែម ហូណារិទ្ធិ និង ម៉ៅ សំរុទ្ធារី ជាតំណាង គឺ :

ប្រាក់កក់ចំនួន៥៤០០ ដុល្លាអាមេរិក ជំងឺចិត្តចំនួន៣.០០០ ដុល្លាអាមេរិក សរុប ៥៧.០០០ ដុល្លាអាមេរិក តតិយជនទាមទារលើសពីនេះ បដិសេធចោល ។ ក្នុងករណីក្រុមហ៊ុន គ្រីស្ទីណា ដែលមានឈ្មោះលឹម ឡេង ជាតំណាងគ្មានប្រាក់សង ត្រូវរឹបអូសប្រាក់កក់ចំនួន១២០០០ដុល្លាអាមេរិក ដែលសល់ពីការទូទាត់ឱ្យឈ្មោះមាស សុគន្ធ និងរឹបអូសទ្រព្យសម្បត្តិក្រុមហ៊ុនគ្រីស្ទីណា លក់ឡាយឡុង ដើម្បីយក

ប្រាក់ទូទាត់សំណងបង្គ្រប់តាមច្បាប់ ។ តាមមាត្រា១ នៃច្បាប់ស្តីពី វិធីអនុវត្តសាលក្រមរដ្ឋប្បវេណី ដែលប្រកាសឱ្យប្រើតាមក្រិត្យលេខ៥១ក្រ ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ១៩៩២ ។

៤-អនុញ្ញាតឱ្យឈ្មោះវេង ឈុនសុាំង មានសិទ្ធិជួលឃ្លាំងម្ចាស់ឃ្លាំងដើមចោទ ឈ្មោះមាស សុគន្ធ តាមការព្រមព្រៀងរបស់គូភាគី ។

៥-ឱ្យក្រុមហ៊ុនគ្រីស្ទីណា ដែលមានឈ្មោះលឹម ឡេង ជាតំណាងបង់ប្រាក់ប្រដាប់ក្តីគឺពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹងចំនួន១.៨០០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ចំនួន ២០០៛ ចំណាយក្នុងកិច្ចស៊ើបសួរចំនួន៥.០០០៛ សរុប ៧.០០០៛ ។ ប្រាក់នេះ កាត់យកពីប្រាក់ដើមចោទបង់រួច ហើយ បើសាលក្រមចូលជាស្ថាពរ ឱ្យចុងចម្លើយសងប្រាក់ទៅដើមចោទវិញ និងឱ្យបង់ពន្ធសមាមាត្រ១% លើទឹកប្រាក់សំណង និងជំងឺចិត្តដែលត្រូវសងឱ្យទៅមាស សុគន្ធ និងឈ្មោះវេង ឈុនសុាំង ប្រាក់នេះដាក់ចូលថវិការដ្ឋចំនួន ៨០% និងដាក់ចូលហិបប្រាក់ក្រឡាបញ្ជីទូទាំងប្រទេសចំនួន២០% បើសាលក្រមនេះ ចូលជាស្ថាពរ ។ តាមច្បាប់ស្តីពីប្រាក់ប្រដាប់ក្តីដែលប្រកាសឱ្យប្រើតាមក្រិត្យលេខ ០៧ក្រ ចុះថ្ងៃទី០៨-០២-១៩៩៣ ។

៦-សាលក្រមនេះ ជំនុំជំរះនឹងប្រកាសជាសាធារណៈចំពោះមុខតំណាងដើមចោទ និងតំណាងតតិយជន និងកំបាំងមុខចុងចម្លើយ ទុករយៈពេលប្តឹងទាស់ និងបើកផ្លូវប្តឹងឧទ្ធរណ៍តាម កំណត់ច្បាប់ ។

បានឃើញបណ្តឹងទាស់ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០០១ របស់ឈ្មោះឌី ប៉ូរីម៉ា មេធាវី តំណាងឱ្យឈ្មោះលឹម ឡុង មិនសុខចិត្ត និងសាលក្រមរដ្ឋប្បវេណីលេខ១៥(ក) ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០០១ របស់តុលាការក្រុងភ្នំពេញ លើចំណុចសាលក្រមទាំងមូល ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ១០៨(ក) ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០០១ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងទាស់ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០០១ របស់មេធាវីប៉ូរីម៉ា ជាមេធាវីការពារ និងជាតំណាងឱ្យលោកលឹម ឡេង ភាគី(ខ) ចំពោះសាលក្រមកំបាំងមុខលេខ១៥(ក)ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០០១ របស់តុលាការក្រុងភ្នំពេញ ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ខ្លះ ទាស់ខុសនឹងគតិច្បាប់ខ្លះ ។

២-បដិសេធសាលក្រមកំបាំងមុខលេខ១៥(ក) ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០០១ របស់តុលាការក្រុងភ្នំពេញចោល ហើយសម្រេចសេចក្តីជាថ្មីដូចខាងក្រោម :

ក-រំលាយប្រការទី៥ នៃកិច្ចសន្យាចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ជាភាសាអង់គ្លេសត្រង់អត្ថន័យឲ្យបង់ប្រាក់ផាកពិន័យ៣% ក្នុង១ខែ លើថ្លៃឈ្នួលឃ្លាំងក្នុងមួយខែ៣០០០ដុល្លាអាមេរិក (មាត្រា៥នៃរដ្ឋធម្មនុញ្ញ) ។

ក១-រំលាយកិច្ចសន្យាចុះថ្ងៃទី១២ខែវិច្ឆិកា ឆ្នាំ១៩៩៧ រវាងភាគី(ក) សូសាមឿន និងមាស សុគន្ធ ជាមួយភាគី(ខ) លឹម ឡេង តំណាងក្រុមហ៊ុនគ្រីស្ទីណាចោល (មាត្រា ១០៧នៃ ច្បាប់កិច្ចសន្យា) ។

ក២- បង្គាប់ឱ្យក្រុមហ៊ុនគ្រីស្ទីណា មានលោកលីម ឡេង ជាតំណាងសងប្រាក់ថ្លៃឈ្នួល ឃ្លាំងពីរខែគឺ ខែកក្កដា និងសីហា ឆ្នាំ២០០០ ចំនួន៦០០០ដុល្លាអាមេរិក និងជំងឺចិត្ត២.០០០ ដុល្លាអាមេរិក សុរប ចំនួន ៨.០០០ដុល្លាអាមេរិក ឱ្យទៅឈ្មោះសូ សាមឿន និងមាស សុគន្ធ ដែលមានឈ្មោះ ម៉ែ វ៉ាន់ឌី ជាតំណាងដោយឱ្យកាត់យកពីប្រាក់កក់០៨ខែចំនួន ២៤០០០ដុល្លា អាមេរិក ដែលលោកលីម ឡេង បានកកនៅដៃដើមចោទឈ្មោះសូ សាមឿន និងឈ្មោះមាសសុគន្ធ ។ ឯប្រាក់កក់នៅសល់ចំនួន១៦.០០០ដុល្លាអាមេរិក ឈ្មោះសូ សាមឿន និងមាស សុគន្ធ ត្រូវប្រគល់ឱ្យឈ្មោះលីម ឡេង ជាតំណាងក្រុមហ៊ុនគ្រីស្ទីណាវិញ ។ ជំងឺចិត្តដើមចោទ សុំលើសពី២.០០០ដុល្លាអាមេរិក បដិសេធចោល ។

ក៣-រឹបអូសប្រាក់ឈ្នួលឃ្លាំងជួលបន្ត ដែលតុលាការឹបអូស ឃាត់ទុកពីឈ្មោះចូវ កាពីន ជាតំណាងនៃឈ្មោះវេង ឈុនសុាំង ក្នុង១ខែ ៣.០០០ដុល្លាអាមេរិក ចាប់ពីខែកញ្ញា ឆ្នាំ២០០០ រហូតមកតាមដីកាសម្រេចតាមពាក្យសុំលេខ ៥៤(ក) ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០០០ ប្រគល់ឱ្យទៅឈ្មោះសូ សាមឿន និងមាស សុគន្ធ ទុកជាថ្លៃឈ្នួលឃ្លាំង ។ ប្រាក់ឈ្នួលឃ្លាំងសល់ពីនេះ១.៥០០ ដុល្លាអាមេរិករៀងរាល់ខែ ត្រូវប្រគល់ឱ្យទៅឈ្មោះលឹម ឡេង តំណាងក្រុមហ៊ុនគ្រីស្ទីណា ជាអ្នក ជួលឃ្លាំងបន្តឱ្យឈ្មោះវេង ឈុនសុាំង ។

ខ/ទទួលពាក្យសុំចូលជាតតិយជន ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០០១ របស់លោក វេងឈុន សុាំង មានមេធាវីហែម ហូរណារិទ្ធី និងកញ្ញាម៉ៅ សំរុទ្ធារី ជាតំណាងទុកជាត្រឹមត្រូវ ។

ខ១-រំលាយចោលនូវកិច្ចសន្យាជួលឃ្លាំងបន្តចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៧ រវាងលោក លឹម ឡេង តំណាងក្រុមហ៊ុនគ្រីះស្ទីណា ជាមួយលោកវេង ឈុនសុាំង មានឈ្មោះចូវ កាពីនជាតំណាងចោល។

ខ២-បង្គាប់ឱ្យលោកលីម ឡេង ជាតំណាងក្រុមហ៊ុនគ្រីស្ទីណា ប្រគល់ប្រាក់កក់៥៤.០០០ ដុល្លាអាមេរិក ឲ្យទៅលោកវេង ឈុនសុាំង មានលោកចូវ កាពីន ជាតំណាងវិញប្រសិនបើគ្មានប្រាក់សងត្រូវរឹបអូសប្រាក់នៅសល់១៦០០០ដុល្លាអាមេរិក ដែលនៅសល់ពីការទូទាត់ឲឈ្មោះមាស សុគន្ធ និងរឹបអូសថ្លៃឈ្នួលឃ្លាំងរៀងរាល់ខែ ដែលតុលាការបានឃាត់ទុកតាមអំណាចដីកាសម្រេចតាមពាក្យសុំលេខ៥៤(ក) ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០០០ ដើម្បីទូទាត់សំណងខាងលើ ។

ខ៣-អនុញ្ញាតឱ្យលោកវេង ឈុនសាំង មានសិទ្ធិជួលឃ្លាំងទំនាស់បន្តពីម្ចាស់ឃ្លាំងសូមឿន និងមាស សុគន្ធ តាមការព្រមព្រៀង ។

៣-ឱ្យលោកលឹម ឡេង តំណាងក្រុមហ៊ុនគ្រីស្ទីណា បង់ប្រាក់ប្រដាប់ក្តី៧.០០០៛ ប្រាក់នេះមានកាត់យកពីប្រាក់ប្រដាប់ក្តី៧.០០០៛ របស់ដើមចោទដាក់ថវិការដ្ឋ និងចំណាយផ្សេងៗ រួចហើយ ហើយតម្រូវឱ្យលឹម ឡេង តំណាងឱ្យក្រុមហ៊ុនគ្រីស្ទីណា សងប្រាក់នេះឱ្យទៅដើមចោទវិញ និងបង្គាប់ឱ្យបង់ពន្ធសមាមាត្រ១% លើទឹកប្រាក់ដែលលោកលឹម ឡេង តំណាងក្រុមហ៊ុនគ្រីស្ទីណា ត្រូវសងទៅលោកសូ សាមឿន និងអ្នកស្រីមាស សុគន្ធ ។

៤-សាលក្រមនេះ សម្រេចសេចក្តី និងប្រកាសជាសាធារណៈនៅចំពោះមុខ តំណាងដើមចោទ មេធាវីតំណាងចុងចម្លើយ និងមេធាវីតំណាងតតិយជន ។ បើកផ្លូវប្តឹងឧទ្ធរណ៍ រយៈពេលពីរខែ គិតពីថ្ងៃប្រកាសសាលក្រមនេះតទៅ ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ២០(ក) ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០០២ របស់មេធាវី លោកឌី បូរីម៉ា តំណាងឱ្យលោកលឹម ឡេង ប្តឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ១០៨(ក)ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០០១ របស់តុលាការក្រុងភ្នំពេញ ត្រង់ចំណុចសេចក្តីសម្រេចនៃសាលក្រមទាំងមូល និងបណ្តឹងឧទ្ធរណ៍២១(ក) ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០២ របស់កញ្ញាម៉ៅ សំវុទ្ធារី មេធាវីតំណាងឲ្យក្រុមហ៊ុន Cambodia H.K ជាតតិយជនខាងភាគីដើមចោទ មិនសុខចិត្ត ត្រង់ចំណុចទីក៣ នៃសាលក្រមទាំងមូលនិងបណ្តឹងឧទ្ធរណ៍លេខ២២(ក) ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០២ មិនសុខចិត្ត ត្រង់ចំណុចទីក៣ នៃសាលក្រម ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ១២៥(ឈ) ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ ដែលមានសេចក្តីសំរេចដូចតទៅ :

១-ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០០២ របស់លោកមេធាវីឌី បូរីម៉ា ការពារឱ្យភាគីចុងចម្លើយឈ្មោះលឹម ឡេង បណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០២ របស់ឈ្មោះម៉ែ វ៉ាន់ឌីតំណាងឲភាគីមាស សុគន្ធ ជាដើមចោទ និងបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០២ របស់មេធាវីម៉ៅ សំវុទ្ធារី ការពារឱ្យតតិយជនឈ្មោះវេង ឈុនសុាំង ទុកជាត្រឹមត្រូវតាម ទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២-តម្កល់សាលក្រមរដ្ឋប្បវេណីលេខ១០៨(ក)ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០០១ របស់តុលាការក្រុងភ្នំពេញ ទុកជាបានការពេញទាំងមូល ។

៣-រឹបអូសប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ចំនួន១៣.០០០៛ គឺពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹង ២.៥៥០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់៤៥០៛ ចំណាយលើការប្រគល់ដីកាកោះ ៥០០០៛ និងលើអាជ្ញាធរតុលាការ ៥.០០០៛ សរុប ១៣.០០០៛ ។

៤-សាលដីកានេះ ជំនុំជំរះនិងប្រកាសជាសាធារណៈចំពោះមុខតំណាងដើមចោទតំណាងតតិយជន ក៏បាំងមុខចុងចម្លើយ បើកផ្លូវប្តឹងតវ៉ាតាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ ៣១០ ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០០២ របស់អ្នកស្រី ស្រី ដានី តំណាងឱ្យចុងចម្លើយ ប្តឹងមិនសុខចិត្តនិងសាលដីការដ្ឋប្បវេណីលេខ ១២៥(ឈ) ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសាលដីកាទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ១៤១ ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០០៣ របស់តុលាការកំពូល ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១-ទទួលបណ្តឹងសាទុក្ខលេខ៣១០ ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០០២ របស់អ្នកស្រី ស្រី ដានី តំណាងឱ្យលោកលឹម ឡេង ទុកជាត្រឹមត្រូវទាំងទម្រង់ និងគតិច្បាប់ ។

២-ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ ១២៥(ឈ)ចុះថ្ងៃទី ២៣ ខែកក្កដា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣-បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ ៣១៤ ចុះថ្ងៃទី ០៣ ខែតុលា ឆ្នាំ២០០២ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤-រឹបអូសប្រាក់ប្រដាប់ក្តីដែលចុងចម្លើយ ។ បានបង់ទុកនៅតុលាការកំពូលចំនួន១៩.០០០៛ គឺៈ

-ពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹងចំនួន៤០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០៛ សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់

-ចំណាយក្នុងកិច្ចប្រគល់ដីកាកោះចំនួន១៥.០០០៛ សរុប១៩.០០០៛ ។ ហើយតម្រូវឱ្យដើមចោទសងប្រាក់ ១៩.០០០៛ ទៅចុងចម្លើយវិញ ។

៥-សាលដីកានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០៣ សាលដីកានេះ ត្រូវបានតុលាការកំពូល បង្វិលសំណុំរឿងលេខ៣១៤ ចុះថ្ងៃទី៣ ខែតុលា ឆ្នាំ២០០២ ទៅសាលាឧទ្ធរណ៍វិញ ដើម្បីចាត់ការតាមច្បាប់ ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ១៣៧(ង) ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារ នៃសេចក្តីសម្រេចដូចតទៅ :

១-ទទួលជំនុំជំរះសំណុំរឿងរដ្ឋប្បវេណីលេខ៥១ ចុះថ្ងៃទី១៨-០៧-២០០៣ របស់សាលាឧទ្ធរណ៍តាមសាលដីការដ្ឋប្បវេណីលេខ១៤១ ចុះថ្ងៃទី០៣-០៧-២០០៣ របស់តុលាការកំពូល ។

២-ក/រំលាយកិច្ចសន្យា ចុះថ្ងៃទី១២-១១-១៩៩៧ រវាងឈ្មោះសូ សាមឿន និងមាស សុគន្ធ ជាមួយក្រុមហ៊ុនគ្រឹស្ទីណា ដែលមានលោកលឹម ឡេង ជាតំណាងចោលជាអសារបង់ ។ ដាក់កំហុសលើភាគីដើមចោទឈ្មោះមាស សុគន្ធ និងសូ សាមឿន ។

ខ/រំលាយកិច្ចសន្យាចុះថ្ងៃទី១៦-១១-១៩៩៧ រវាងក្រុមហ៊ុនគ្រឹស្ទីណាដែលមាន លោកលឹម ឡេង ជាតំណាងជាមួយលោកជូ កាពីន និងលោកវេង ឈុនស៊ាំង ។ ដាក់កំហុស លើឈ្មោះវេង ឈុន-ស៊ាំង និងចូ កាពីន ។

៣-ទទួលបណ្តឹងតបចុះថ្ងៃទី០៧-០៩-២០០១ របស់ចុងចម្លើយឈ្មោះលីម ឡេង ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

៤-បង្គាប់ឱ្យឈ្មោះមាស សុគន្ធ និងប្តីឈ្មោះសូ សាមឿន ប្រគល់ប្រាក់កក់សំរាប់ រយៈពេល ៨ខែ ស្មើនឹង២៤.០០០USD (ពីរម៉ឺនបួនពាន់ដុល្លាអាមេរិក) កំរៃការខូចខាតចំនួន១២៦.០០០USD (មួយ

រយម្ភៃប្រាំមួយពាន់ដុល្លាអាមេរិក) និងសំណងជំងឺចិត្តចំនួន៥.០០០USD(ប្រាំពាន់ដុល្លាអាមេរិក) ទៅឱ្យឈ្មោះលឹម ឡេង ដែលជាតំណាងឱ្យក្រុមហ៊ុនគ្រឹះស្ទីណា នៅពេលដែលសាលដីកានេះចូលជាស្ថាពរ។

៥-ក្នុងករណីឈ្មោះមាស សុគន្ធ និងឈ្មោះសូ សាមឿន គ្មានប្រាក់សងអនុញ្ញាតឱ្យរបអូសទ្រព្យសម្បត្តិរបស់ឈ្មោះនេះ លក់ឡាយឡុង ដើម្បីយកប្រាក់សងចុងចម្លើយ បើពុំគ្រប់ឬរឹងរូស អនុញ្ញាតឱ្យដាក់គុកបង្ខំលើរូបកាយលើឈ្មោះមាស សុគន្ធ និងសូ សាមឿន តាមមាត្រា១៣៣ ច្បាប់ស្តីពីនីតិវិធីអនុវត្តសាលក្រមរដ្ឋប្បវេណី ។

៦-អនុញ្ញាតិឱ្យឈ្មោះលឹម ឡេង ជាចុងចម្លើយកាត់យកប្រាក់កក់ចំនួន ៥៤.០០០USD(ប្រាំមឺុនបួនពាន់ដុល្លាអាមេរិក) ដែលឈ្មោះវេង ឈុនសុាំង និងជូ កាពីន បានកក់ទុកនៅពេលសាលដីកានេះចូលជាស្ថាពរ ។

៧-ក/បង្គាប់ឈ្មោះមាស សុគន្ធ និងសូ សាមឿន បង់ពន្ធសមាមាត្រ១% លើទឹកប្រាក់ដែលបានសម្រេចក្នុងចំណុចទី៤ នៃសាលដីការនេះ ។

ខ/បង្គាប់ឱ្យឈ្មោះវេង ឈុនសុាំង និងចូវ កាពីន បង់ពន្ធសមាមាត្រ១% លើទឹកប្រាក់ដែលបានសម្រេចក្នុងចំណុចទី៦ នៃសាលដីកានេះ ។

៨-សាលដីកានេះ ជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខតំណាងចុងចម្លើយ កំបាំងមុខដើមចោទ មេធាវីដើមចោទ និងតតិយជន ។ បើកផ្លូវប្តឹងតវ៉ាក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងទាស់លេខ១១៨ ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ ២០០៣ របស់អ្នកស្រីមាស សុគន្ធមិនសុខចិត្តនិងសាលដីការដ្ឋប្បវេណីលេខ១៣៧(ង) ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចនៃសាលដីកាទាំងមូល និងបណ្តឹងទាស់លេខ១១៩ ចុះថ្ងៃ ទី១០ ខែតុលា ឆ្នាំ ២០០៣ របស់កញ្ញា ម៉ៅ សំរុទ្ធារី ជាមេធាវីការពារឱ្យលោកជូ កាពីន ជាតតិយជន មិនសុខចិត្ត ត្រង់ចំណុចទី៦ និងទី៧(ខ) នៃសាលដីកា ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ១៥៩(ង)ចុះថ្ងៃទី៣១ ខែវិច្ឆិកា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងទាស់ចុះថ្ងៃទី១០-១០-២០០៣ របស់ឈ្មោះមាស សុគន្ធ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោល ដោយផ្ទុយនឹងគតិច្បាប់ ។

២-ទទួលពាក្យបណ្តឹងទាស់ ចុះថ្ងៃទី១០-១០-២០០៣ របស់ឈ្មោះម៉ៅ សំរុទ្ធារី មេធាវីតំណាងឱ្យតតិយជនឈ្មោះចូវ កាពីន ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់ ។

៣-តម្កល់សាលដីការដ្ឋប្បវេណីលេខ១៣៧(ង) ចុះថ្ងៃទី១១-០៩-២០០០របស់សាលាឧទ្ធរណ៍ទុកជាបានការ ។

៤-សាលដីកានេះដំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខតំណាងឱ្យដើមចោទឈ្មោះម៉ៃ វ៉ាន់ឌី មេធាវីការពារឱ្យដើមចោទលោកម៉ៅ សុភារិទ្ធ តំណាងចុងចម្លើយលោកស្រី ស្រី ដានី មេធាវីការពារឱ្យចុងចម្លើយលោកឌី បូរីម៉ា កំបាំងមុខឈ្មោះម៉ៅ សំរុទ្ធារី មេធាវី តំណាងឱ្យតតិយជនឈ្មោះដូ កាពិន តែចាត់ទុកជាចំពោះមុខ ។បើកផ្លូវប្តឹងសាទុក្ខក្នុងកំណត់ច្បាប់។

បានឃើញបណ្តឹងសាទុក្ខលេខ៣៧៦ ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០០៣ របស់អ្នកស្រី ស្រី ដានី មិនសុខចិត្តនិងសាលដីការដ្ឋប្បវេណីលេខ១៥៩(ង) ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៣ លើសេចក្តីសម្រេចទាំងមូល និងបណ្តឹងសាទុក្ខលេខ២១៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៣ របស់មេធាវីកញ្ញា ម៉ៅ សំរុទ្ធារី ការពារឱ្យតតិយជន មិនសុខចិត្តលើសេចក្តីសម្រេចទាំងមូល និងបណ្តឹងសាទុក្ខលេខ២១២ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០០៣ របស់អ្នកស្រីមាស សុគន្ធ មិនសុខចិត្តលើសេចក្តីសម្រេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីរបៀបលេខ១៩៦ ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០០៤ របស់តុលាការកំពូល ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១-ចាត់របៀបធ្វើការអង្កេតបន្ថែម ។

២-សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០០៤ ។

បានឃើញសារណាតប និងការពារ ចុះថ្ងៃទី១៨-០២-២០០៤ របស់លោកម៉ៅ សុភារិទ្ធ មេធាវីការពារឱ្យអ្នកស្រីមាស សុគន្ធ ។

បានឃើញសារណាតប និងការពារចុះថ្ងៃទី០៥-០៣-២០០៤ របស់កញ្ញាម៉ៅ សុភារិទ្ធ មេធាវីការពារឱ្យតតិយជន ។

បានឃើញសារណាការពារ ចុះថ្ងៃទី២៧-០១-២០០៤ របស់លោកកុំ ប៊ុតផាន់ មេធាវីការពារឱ្យអ្នកស្រី ស្រី ដានី ។

បានឃើញសារណាតប ចុះថ្ងៃទី២២-០៣-២០០៤ របស់លោកកុំ ប៊ុនផាន់ មេធាវីការពារ ឱ្យអ្នកស្រី ស្រី ដានី ។

បានឃើញសារណាតប ចុះថ្ងៃទី០៩-០៣-២០០៤ របស់លោក ប៊ុនផាន់ មេធាវីការពារឱ្យ អ្នកស្រី ស្រី ដានី ។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា: រឿងនេះជាវិវាទប្តឹងសុំរំលាយកិច្ចសន្យា។

សូមក្រុមប្រឹក្សាជំនុំជំរះ ពិនិត្យ និងសម្រេច ។

បានស្តាប់ចម្លើយរបស់ឈ្មោះម៉ៃ វ៉ាន់ឌី នាពេលសវនាការថា : ខ្លួនប្តឹងសាទុក្ខមិនសុខចិត្ត និងសេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍ ដោយសម្រេចសេចក្តីមានភាពអយុត្តិធម៌ ។ ខ្លួនសុំឱ្យលោក លឹម ឡេង

បង់ថ្លៃឈ្នួលជួលឃ្លាំងគ្រប់ចំនួនដែលមិនបានបង់ចាប់ពីខែ៧-៨ ឆ្នាំ២០០០ និងខែ១១ ឆ្នាំ២០០១ រហូតដល់ខែមេសាឆ្នាំ២០០២ ដែលមានទឹកប្រាក់ចំនួន២៤.០០០ដុល្លាអាមេរិក និងសុំរំលាយកិច្ចសន្យាចុះថ្ងៃទី១២-១១-១៩៩៧ចាល និងសុំឱ្យតុលាការកំពូលបដិសេធសាលដីការបស់សាលាឧទ្ធរណ៍ចោល។

បានស្តាល់ចម្លើយរបស់ឈ្មោះលឹម ឡេង នាពេលសវនាការថា : ក្នុងការជួលឃ្លាំងនេះ មានកិច្ចសន្យារយៈពេល១០ឆ្នាំ ខ្លួនបានបង់ថ្លៃឈ្នួលជាង២ឆ្នាំហើយ ពុំដែលអាក់ខានទេ ចំពោះប្រាក់ឈ្នួលខែកក្កដា-សីហា ឆ្នាំ២០០០ ខ្លួនយកទៅបង់ តែគេពុំព្រមទទួល ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកម៉ៅ សុភារិទ្ធជាមេធាវីការពារឱ្យដើមចោទ បានលើកឡើងថា៖ ខ្លួនសុំតម្កល់ខ្លឹមសារសេចក្តីសន្និដ្ឋាននាពេលសវនាការថ្ងៃទី០៧-៩-២០០៤ដដែល។ បញ្ហាកំហុសគឺបណ្តាលមកពីភាគីលោកលឹម ឡេង ពុំបានបង់ប្រាក់ឈ្នួលមកឱ្យកូនក្តីខ្លួន ហើយការដែលលោកលឹម ឡេង យកលុយមកឱ្យកូនក្តីនៅសង្កាត់ពុំពិតតែ ព្រោះថា ការចូលផ្សះផ្សានៅសង្កាត់ គឺនិយាយគ្នាពីប្រាក់ពិន័យ ដែលមានពីរភាសា ខ្មែរ និងអង់គ្លេស ខ្មែរ ពិន័យ៣% ក្នុង១ថ្ងៃ ភាសាអង់គ្លេស៣% ក្នុង១ខែ ដូច្នេះការដែលថា កូនក្តីខ្លួនពុំព្រមទទួលប្រាក់នោះពុំពិតទាំងស្រុង ព្រោះថា កូនក្តីខ្លួនជួលឃ្លាំងចង់បានលុយ ។

<u>**សំណូមពរ**</u> - សុំរំលាយកិច្ចសន្យាចុះថ្ងៃទី១២-១១-១៩៩៧ ចោល

-សុំឱ្យលោកលឹម ឡេង សងប្រាក់គ្រប់ចំនួនដែលពុំបានបង់មកឱ្យកូនក្តីខ្លួន ។

-សុំទាមទារជំងឺចិត្តខាតបង់ពេលវេលានិងសោហ៊ុយផ្សេងៗគិតជាទឹកប្រាក់ចំនួន៦.០០០ ដុល្លារ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកឌី បូរីម៉ា ជាមេធាវីការពារឱ្យចុងចម្លើយ បានលើកឡើងថា : អ្នកស្រីមាស សុគន្ធ បានចេញលិខិតព្រមាន ដល់កូនក្តីខ្លួន ហើយអ្នកស្រីដានី បានមកជួបខ្លួនឱ្យជួយផ្សះផ្សាពីបញ្ហាទំនាស់ជាភាសាខ្មែរ និងអង់គ្លេស ហើយភាគីទាំងសងខាងបានសុខចិត្ត យកមួយខែ៣% និងចុះដល់១ខែ២% ដូច្នេះលោកលឹម ឡេង យកលុយមកបង់ឱ្យ តែខុសគ្នាតែ បន្តិចទេត្រង់ថា ពិន័យកន្លងមកគិតគូយ៉ាងម៉េច ។ ពេលនោះភាគីមាស សុគន្ធ ដើរចេញ ហើយសង្កាត់ថា លោកមេធាវីទុកប្រាក់នេះហើយ ។

សុំតម្កល់សាលដីការបស់សាលាឧទ្ធរណ៍ទុកជាបានការ ។

សុំបន្តកិច្ចសន្យាបន្តទៀត ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកទី គឹមស្រ៊ាន ជាមេធាវីការពារឱ្យចុងចម្លើយ បានលើកឡើថា : កិច្ចសន្យាជាច្បាប់របស់គូភាគីក្នុងប្រការ៥ ឃើតយ៉ាវជាច្រើនដង ទើបសុំផ្អាកកិច្ចសន្យា ហើយកូនក្តីខ្លួនទើបតែឃើតម្តងទេ ដូច្នេះកូនក្តីខ្លួន ពុំមានកំហុសទេ ។

ដូច្នេះសុំឱ្យតុលាការកំពូល តម្កល់សាលដីការបស់សាលាឧទ្ធរណ៍ ទុកជាបានការ និងសុំបន្តកិច្ចសន្យាតទៅទៀត ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយគូភាគី និងសេចក្តីសន្និដ្ឋានការពាររបស់មេធាវីគូភាគី

-ក្រោយពីបានពិភាក្សត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ២១២ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០០៣ របស់អ្នកស្រីមាស សុគន្ធ និងបណ្តឹងសាទុក្ខលេខ២១៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៣ របស់មេធាវីម៉ៅ សំរុទ្ធារី តំណាងឱ្យលោកជូ កាពីន និងបណ្តឹងសាទុក្ខលេខ៣៧៦ ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០០៣ របស់អ្នកស្រី ស្រី ដានី តំណាងឱ្យលោកលឹម ឡេង ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការ កំពូលអាចលើករឿងនេះ មកជំនុំជំរះបាន ដោយយោងតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ។

-យល់ឃើញថា វិវាទរវាងលោកលឹម ឡេង ជាមួយលោកជូ កាពីន និងលោកវេង ឈុនសុាំង ត្រូវបានគូភាគីព្រមព្រៀងស្រុះស្រួលគ្នា បញ្ហាទំនាស់ត្រឹមប្រគល់ប្រាក់កក់ ចំនួន៥៤.០០០ដុល្លាអាមេរិកឱ្យលោកលឹម ឡេង ផ្តាច់ហើយ នៅពេលសវនាការនៅតុលាការកំពូល កាលពីថ្ងៃទី០៧-០៩-២០០៤ និងសម្រេចតាមការព្រមព្រៀងគ្នានេះ ។

-យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សម្រេចឱ្យដើមចោទសងប្រាក់ ១២៦,០០០ ដុល្លាអាមេរិក និងជំងឺចិត្តចំនួន៥.០០០ដុល្លាអាមេរិក ដោយអាងហេតុថា ដើមចោទរំលោភកិច្ចសន្យាធ្វើឱ្យខូចខាតផលប្រយោជន៍ចុងចម្លើយនោះជាការពុំត្រឹមត្រូវទេ ពីព្រោះថា :

-តាមប្រការ៥ នៃកិច្ចសន្យាចុះថ្ងៃទី១២-១១-១៩៩៧ ចែងថា បើភាគីលោកលឹម ឡេង មិនបានបង់ថ្លៃឈ្នួលច្រើនសាចទៀងទាត់ ដើមចោទមានសិទ្ធិផ្អាកកិច្ចសន្យា ។ ចុងចម្លើយខកខានបង់ប្រាក់ពីខែ៧-១៩៩៨ ម្តងរួចហើយ ហើយនៅខែ៧និងខែ៨ ឆ្នាំ២០០០ ចុងចម្លើយខកខានបង់ម្តងទៀត ។ ម៉្យាងទៀត កិច្ចសន្យារវាងលោកលឹម ឡេង និងលោកជូ កាពិន និងលោកវេង ឈុនសុាំង មានរយៈពេលតែ៥ឆ្នាំប៉ុណ្ណោះ ហើយតតិយជនក៏បានសុំឈប់ជួលឃ្លាំងនេះ តាំងពីថ្ងៃទី០១-០៤-២០០២ ទៅហើយ ។ ដូច្នេះតុលាការ ពុំត្រូវផ្តល់ផលប្រយោជន៍ឱ្យ ចុងចម្លើយរហូតដល់១០ឆ្នាំទេ ។

-យល់ឃើញថាមានភស្តុតាងគ្រប់គ្រាន់ថា ចុងចម្លើយពុំបានបង់ថ្លៃឈ្នួលឱ្យដើមចោទ ចំនួន៨ខែ ត្រូវជា៨ខែ x ៣.០០០ដុល្លាអាមេរិក= ២៤.០០០ដុល្លាអាមេរិក ។ ប៉ុន្តែដើមចោទបូន ទទួលប្រាក់កក់ចំនួន ២៤.០០០ដុល្លាអាមេរិក ដូច្នេះគប្បីកាត់កងប្រាក់ឈ្នួលនេះជាមួយនឹងប្រាក់កក់។ ម៉្យាងទៀតប្រាក់ចំណេញពីតតិយជន ចុងចម្លើយបានព្រមព្រៀងគ្នាបញ្ចប់ទំនាស់ហើយ ។

-យល់ឃើញថា នៅពេលសវនាការនេះ គូភាគីសុទ្ធតែអះអាងថា ខ្លួនពុំអាចបន្តអនុវត្ត កិច្ចសន្យាបានទៀតទេ ។ ដូច្នេះការដែលសាលាឧទ្ធរណ៍សម្រេចរំលាយកិច្ចសន្យាចោលនោះ ជាការត្រឹមត្រូវហើយ។

- យល់ឃើញថា តតិយជនពុំបានមកចូលរួមនាសវនាការនេះទេ ដូច្នេះតុលាការកំពូល ជំនុំជំរះកំបាំងមុខ ចាត់ទុកជាចំពោះមុខ ។

-យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ១៥៩ (ង) ចុះថ្ងៃទី២១-១១-២០០៣ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចសេចក្តីមកនេះមានលក្ខណៈ ត្រឹមត្រូវទាំងទម្រង់ទាំងគតិច្បាប់ហើយ លើកលែងតែចំណុចទី៤និងទី៧នៃសាលដីកាកំបាំងមុខរបស់សាលាឧទ្ធរណ៍ ដែលត្រូវទុកជាមោឃៈ ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តីចំពោះមុខគូក្តី កំបាំងមុខតតិយជន ចាត់ទុកជាចំពោះមុខ

១- ទទួលបណ្តឹងសាទុក្ខលេខ២១២ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០០៣ របស់អ្នកស្រីមាសសុគន្ធ ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-ទទួលបណ្តឹងសាទុក្ខលេខ២១៤ ចុះថ្ងៃទី៣១-១២-២០០៣ របស់មេធាវីម៉ៅ សំវុទ្ធារី និងបណ្តឹងសាទុក្ខលេខ៣៧៦ ចុះថ្ងៃទី០៣-១២-២០០៣របស់អ្នកស្រី ស្រី ដានី ទុកជាត្រឹមត្រូវ តាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

៣-តម្កល់សាលដីការដ្ឋប្បវេណីលេខ១៥៩ (ង) ចុះថ្ងៃទី២១-១១-២០០៣ របស់សាលាឧទ្ធរណ៍ ទុកជាបានការ លើកលែងតែចំណុចទី៤ និងទី៧ នៃសាលដីកាកំបាំងមុខរបស់សាលាឧទ្ធរណ៍ ដែលត្រូវទុកជាមោឃៈ ។

៤-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន៥៧.០០០៛ ដែលអ្នកស្រីមាស សុគន្ធ បានបង់ចំនួន១៩.០០០៛ និងលោកលឹម ឡេង បានបង់ចំនួន៣៨.០០០៛ ទុកនៅតុលាការកំពូល គឺ :

-ពន្ធចុះបញ្ជីក្តីនឹងពន្ធហ្នឹងចំនួន៤.០០០៛ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០៛ សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់.

-ចំណាយលើកិច្ចប្រគល់ដីកាកោះចំនួន១៥.០០០៛ សរុប១៩.០០០៛ នៅសល់៣៨.០០០៛ ប្រគល់ឱ្យលោកមាស សុគន្ធ ១៩.០០០៛ និងប្រគល់ឱ្យលោកលឹម ឡេង ១៩.០០០៛ ។

៥-សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០០៥ ។